# ព្រះរាជក្រឹត្យ

នស/រកត/០៤១៧/៣៩៦

## ស្តីពី

## គណៈកម្មការជាតិយុណេស្កូកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋ បូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សា ដែលស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យស្ថិតនៅក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៥៧ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១ រូប | អនុប្រធាន |
| ៣- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មួយចំនួន | សមាជិក |
| ៤- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១ រូប | សមាជិក |
| ៥- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប | សមាជិក |
| ៦- តំណាងក្រសួងព័ត៌មាន ១ រូប | សមាជិក។ |

សមាសភាពជាក់ស្តែង នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២.-**

គណៈកម្មការជាតិយូណេស្កូកម្ពុជា មានតួនាទីនិងភារកិច្ច ដូចតទៅ÷

- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីបញ្ហាទាំងឡាយ ដែលទាក់ទងនឹងយូណេស្កូនិងកម្មវិធីរបស់យូណេស្កូ
- បំពេញតួនាទីជាភ្នាក់ងារទាក់ទងរវាងយូណេស្កូ ជាមួយក្រសួង ស្ថាប័ន អង្គការ និងបុគ្គលនានា ដែលយកចិត្តទុកដាក់បំពេញការងារ ដើម្បីជំរុញឱ្យមានការរីកចម្រើនផ្នែកអប់រំ វិទ្យាសាស្ត្រ វប្បធម៌ និងព័ត៌មាននៅកម្ពុជា
- ធានានូវការចូលរួមយ៉ាងសកម្មរបស់កម្ពុជា ក្នុងកម្មវិធីចូលរួមជាមួយគ្នារបស់យូណេស្កូ ដោយធ្វើការសម្របសម្រួលជ្រើសរើសគម្រោងអាទិភាពទាំងឡាយ ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានា
- ជួយរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា អំពីការជ្រើសរើសបេក្ខជនសម្រាប់កម្មវិធីអាហារូបករណ៍
- ជួយរាជរដ្ឋាភិបាលក្នុងការរៀបចំ និងការចូលរួមសម័យប្រជុំសន្និសីទទូទៅ និងការប្រជុំអន្តររដ្ឋាភិបាលផ្សេងៗទៀត ជាពិសេសជាមួយគណៈកម្មការទាំងនោះ ក្នុងកម្មវិធីរួមគ្នា និងសិក្សាអំពីបញ្ហាទាំងឡាយ ដែលមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា
- បំពេញភារកិច្ចផ្សេងទៀត ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធដល់គណៈកម្មការជាតិយូណេស្កូកម្ពុជា និងគណៈកម្មការយូណេស្កូតំបន់និងយូណេស្កូរួម។

**មាត្រា៣.-**

គណៈកម្មការជាតិយូណេស្កូកម្ពុជា មានសិទ្ធិរៀបចំមហាសន្និបាតយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដែលដឹកនាំដោយប្រធាន ឬអនុប្រធាន ព្រមទាំងការប្រជុំដទៃទៀត តាមការសម្រេចរបស់ប្រធាន ឬតាមការស្នើសុំពីសមាជិកអចិន្ត្រៃយ៍របស់គណៈកម្មការ។

**មាត្រា៤.-**

គណៈកម្មការជាតិយូណេស្កូកម្ពុជា មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួន តាមការចាំបាច់។

គណៈកម្មការជាតិយូណេស្កូកម្ពុជា មានអគ្គលេខាធិការដ្ឋានមួយរួមគ្នាជាមួយគណៈកម្មាធិការជាតិបេតិកភណ្ឌ

ពិភពលោក ធ្វើជាសេនាធិការ ដើម្បីបំពេញការងាររបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥.–**

គណៈកម្មការជាតិយូណេស្កូកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីបំពេញការងាររបស់ខ្លួន។

**មាត្រា៦.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧.–**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០៤១៧.៣៧៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៤០១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**